# កិច្ចតែងការបង្រៀន

**ថ្នាក់ទី.៦ មុខវិជ្ជា :** ភាសាខ្មែរ

**ចំណងជើង :** អំណាន

**ឯកសារ** :សៀវភៅសិស្ស ទំព័រ១៥២.បោះពុម្ពឆ្នាំ.២០០១។

**រយៈពេល :** ពីរម៉ោង(៩0នាទី)

**១-វត្ថុបំណង :**

1-ចំណេះដឹង : សិស្សប្រាប់ពាក្យគន្លឹះចំនួន៥ពាក្យ ពន្យល់ពាក្យចំនួន៣ពាក្យ ប្រាប់ពីខ្លឹមសារលំអិតក្នុងអត្ថបទ ការអានអត្ថបទដោយគោរពសញ្ញាសម្ព័នបានត្រឹមត្រូវតាមរយៈ រូបភាព ឧទាហរណ៍របស់គ្រូការពិភាក្សាក្រុម និងការអានជាបុគ្គល ។

2-បំណិន:សិស្សកំណត់ពីលំដាប់លំដោយនៃខ្លឹមសារអត្ថបទ អានតាមសញ្ញាសម្ព័ន្ធបានត្រឹមត្រូវតាមរយៈរៀបកថាខ័ណ្ឌ និងអានប្រឡងប្រណាំងតាមក្រុម។

3-គតិយាបថ : ចេះសហការគ្នាក្នុងការសម្រេចកិច្ចការអ្វីមួយ។

**២-សម្ភារ :** អត្ថបទទំព័រទី១៥២ ល្បះក្នុងកថាខ័ណ្ឌដែលកាត់ដាច់ពីគ្នា។

**៣- ដំណើរការបង្រៀន:**

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| -សួរបញ្ជាក់វត្តមាន<br>-ឱ្យសិស្សសម្រួលអារម្មណ៍ | **ជំហានទី១**<br>-ពិនិត្យវត្តមាន<br>-ធ្វើចលនាដៃជើង | -សិស្សចូលរួមត្រួតពិនិត្យ<br>-សិស្សក្រោកឈរពត់ដៃពត់ជើង |
| -គ្រូឱ្យសិស្ស៣នាក់យកកិច្ចការចាស់មកដាក់ឱ្យគ្រូកែ ។<br><br>-អានអត្ថបទទំព័រ១៣៨១ចប់<br><br>-តើកសិករខ្មែរចូលចិត្តដាំអ្វីខ្លះ ? | **ជំហានទី២**<br>**-កែកិច្ចការចាស់**<br>-ពាក្យគន្លឹះ ៥ ពាក្យជាពាក្យផ្ញើជើងនឹងជើងក្នុងអត្ថបទទំព័រ១៣៨។<br><br>**-រំលឹកមេរៀនចាស់**<br>-អត្ថបទទំព័រ១៣៨<br>**-ទំនាក់ទំនងមេរៀន**<br>ដំណាំ:ពោត សណ្តែក ស្រូវ ដំឡូង .......។ | -សិស្សឡើងយកសៀវភៅឱ្យគ្រូកែ និង ឡើងធ្វើកំណែលើក្តារខៀន។<br>-សិស្សដូរគ្នាកែ<br><br>-អានបណ្តាក់គ្នាតាមក្រុម១ចប់<br><br>-ឆ្លើយតាមជាក់ស្តែង |

| | **ជំហានទី៣** | |
|---|---|---|
| -គ្រូបញ្ជាក់ថាមេរៀនថ្ងៃនេះ ទាក់ទងនឹងដំណាំទាំងនេះតើជាដំណាំអ្វី?ឱ្យសិស្សទស្សន៍ទាយដោយ ចាប់យករុក្ខជាតិណាមួយ ១ក្រុម១មុខតាមការគិត។ | -ដំណាំស្រូវ | - សិស្សចាប់យក ស្រូវ សណ្តែកបាយ ពោត ស្មៅ ដំឡូងមី តាមគំនិតប៉ាន់ស្មានរបស់គេ។<br>-សិស្សផ្ទៀងផ្ទាត់ |
| -គ្រូបិទរូបស្រូវផ្កាប់លើក្តារខៀន មិនឱ្យសិស្សឃើញ បន្ទាប់មកទៀត គ្រូឱ្យគេឡើងបើករូបដើម្បីផ្ទៀងផ្ទាត់ ។ | | -សិស្សឆ្លើយ |
| -ឱ្យសិស្សដាក់ចំណងជើង | -ដំណាំស្រូវ | -សិស្សសង្កេត |
| -គ្រូសរសេរចំណងជើងលើ ក្តារខៀនតែមិនពេញលេញ | -ដំ...........វ | -សិស្សសរសេរចំណងជើងបំពេញ |
| -ឱ្យសិស្សឡើងសរសេរបំពេញ | -ដំណាំស្រូវ | -សិស្សអានបំពេញស្ងាត់ៗ |
| -ឱ្យសិស្សអានស្ងាត់លើកទី១ | -អត្ថបទទំព័រ១៥២ ចំណងជើង ដំណាំស្រូវ ចាប់ផ្តើមពីដំណាំ.........<br>.......................................<br>គ្មានភ្លៀងគ្រប់ គ្រាន់ ។ | -សិស្សសរសេរចំណងជើង ពេញលេញ<br>-សិស្សអានស្ងាត់នូវអត្ថបទ ទាំងស្រុង ។<br>-សិស្សឡើងសរសេរ |
| -ឱ្យសិស្សជ្រើសរើសពាក្យពិបាក ៦ពាក្យ | ស្រូវពង្រោះ សន្ទូង ទិន្នផល អាជីវកម្ម ឧបករណ៍ ស្នាច ។ | -សិស្សអាន កែអក្ខរាវិរុទ្ធ និង ធ្វើអក្ខរាវិញ្ញាស |
| -គ្រូឱ្យសិស្សអាន កែអក្ខរាវិរុទ្ធ និង ប្រកបពាក្យ | | |
| -គ្រូជ្រើសរើស៣ពាក្យមកលើក ឧទាហរណ៍ពន្យល់ | | |
| -ឧទាហរណ៍ទី១:ឆ្នាំមុនពូសំធ្វើស្រែ ក្នុងដី១ហិកតាទទួលបានទិន្នផល ៣តោនប៉ុន្តែឆ្នាំនេះគាត់ទទួល បានទិន្នផលផល៥តោន។ ដូច្នេះទិន្នផលស្រូវគាត់កើនលើស | -ទិន្នន័យ( នាម )=ផលដែល | -សិស្សពន្យល់ន័យដោយវិភាគ |

| | | |
|---|---|---|
| ឆ្នាំមុន ។<br>តើពាក្យទិន្នផលមានន័យដូចម្ដេច?<br>-ឧទាហរណ៍ទី២:គ្រូបង្ហាញអំបោស ដែកចូក អំបោសជូត រួចសួរ<br>-តើឧបករណ៍ទាំងនេះជាឧបករណ៍ សម្រាប់ធ្វើអ្វី?<br>-ឧបករណ៍មានន័យដូចម្ដេច?<br><br>-ឧទាហរណ៍ទី៣:សុខមានលុយ ១0000រៀលសុខចង់បានអាវ ដែលមានតម្លៃ១២000រៀលតើ សុខមានលទ្ធភាពទិញបានទេ?<br>-តើត្រូវមានប៉ុន្មានទៀតទើប ទិញបាន?តើពាក្យលទ្ធភាពមាន ន័យដូចម្ដេច? | ទទួលបាន ។<br>ឧ:ជីតាខ្ញុំដាំល្ហុបានទិន្នផលខ្ពស់<br><br>-ឧបករណ៍(នាម)=វត្ថុ សម្រាប់ប្រើប្រាស់<br>ឧ: ខ្ញុំទម្លាប់ទុកដាក់ឧបករណ៍ សិក្សាក្នុងកាបូបរបស់ខ្ញុំ។<br><br>លទ្ធភាព(ន)=ភាពដែលអាច ធ្វើបាន<br>ឧ:ប្រសិនបើខ្ញុំប្រឡងជាប់ ខ្ញុំមានលទ្ធភាពរៀននៅថ្នាក់ ទី៧ ។ | លើឧទាហរណ៍របស់គ្រូ និង លើកឧទាហរណ៍<br><br>-ឧបករណ៍អនាម័យ<br>-សិស្សពន្យល់ន័យដោយវិភាគ លើឧទាហរណ៍ទី២របស់គ្រូ និងលើកឧទាហរណ៍<br><br>-សុខគ្មានលទ្ធភាពទិញទេ<br><br>-សិស្សពន្យល់ន័យដោយវិភាគ លើឧទាហរណ៍ទី៣របស់គ្រូនិង លើកឧទាហរណ៍ |
| -ឱ្យសិស្សអានស្ងាត់លើកទី២<br>-គ្រូចែកក្រុមឱ្យពិភាក្សាសំណួរ ។<br>ជួរទី១<br>-តើអត្ថបទនេះចែកជាប៉ុន្មាន កថាខ័ណ្ឌ ?កថាខ័ណ្ឌទី១មានន័យ ដូចម្ដេច?<br>ជួរទី២<br>-តើអត្ថបទនេះចែកជាប៉ុន្មាន កថាខ័ណ្ឌ ?កថាខ័ណ្ឌទី២មានន័យ | -អត្ថបទទំព័រទី១៥២ ចែកជា៣កថាខ័ណ្ឌ<br>-កថាខ័ណ្ឌទី១: ដំណាំធំបំផុត ...................ធ្វើស្រែប្រាំង។<br>-ខ្លឹមសារគឺ:ដំណាំស្រូវធ្វើ គ្រប់ទីកន្លែងទាំងរដូវប្រាំងនិង វស្សា។<br>-កថាខ័ណ្ឌទី២:ស្រូវវស្សា..... | -សិស្សអានស្ងាត់លើកទី២<br>-ចាប់ដៃគូ<br><br>-ពិភាក្សាក្រុម កត់ត្រា រាយការណ៍ កែលំអ ។ |

| | | |
|---|---|---|
| ដូចម្តេច?<br>ជួរទី៣<br>-តើអត្ថបទនេះចែកជាប៉ុន្មានកថាខ័ណ្ឌ ?កថាខ័ណ្ឌទី៣មានន័យដូចម្តេច?<br><br>-គ្រូឱ្យសិស្សអានឮជាបុគ្គល៥នាក់ និងកែលំអការអានរបស់សិស្ស ។ | ..............ដល់ស្រូវទុំ ។<br>-ខ្លឹមសារគឺៈប្រភេទដំណាំស្រូវដែលធ្វើនៅរដូវប្រាំង និង វស្សា ។<br>ធ្វើ<br>-កថាខ័ណ្ឌទី៣ៈកសិកម្ម.......<br>..............ភ្លៀងគ្រប់គ្រាន់ ។<br>-ខ្លឹមសារគឺៈ របៀបធ្វើស្រែនៅប្រទេសកម្ពុជា ។ | -សិស្សអានជាបុគ្គលដោយគោរពតាមសញ្ញាសម្ព័ន្ធ។ |
| -គ្រូចែកអត្ថបទដែលកាត់ជាកំណាត់រួចរៀបតាមលំដាប់លំដោយ<br>-ឱ្យសិស្សអានបណ្តាក់គ្នាជាបុគ្គល និងតាមក្រុម ។ | **ជំហានទី៤**<br>-ពង្រឹងចំណេះដឹង<br>-អត្ថបទ ដំណាំស្រូវ | -រៀបអត្ថបទតាមក្រុម<br>-អានបណ្តាក់គ្នា<br>កំណាត់រួចរៀបតាមលំដាប់លំដោយ<br>-ឱ្យសិស្សអានបណ្តាក់គ្នាជាបុគ្គល និងតាមក្រុម ។ |
| -ចូរសរសេរពាក្យដែលប្រកបនឹងជើង រ ឱ្យបាន៧ពាក្យ<br>អាន និង ធ្វើអក្ខរវិញ្ញាស<br><br>-ចូររៀនអានអត្ថបទទំព័រ១៥៣<br>ពីការបញ្ចេញយោបល់ខ្លីៗ | **ជំហានទី៥**<br>**- កិច្ចការផ្ទះ**<br><br>**-បណ្តាំផ្ញើ** | -សិស្សអនុវត្តនៅផ្ទះ<br><br>-សិស្សអនុវត្តនៅផ្ទះ |